# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៧ .អនក្រ. បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥២អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៤៩អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណង ដូចតទៅ ៖

- ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងកម្មវិធីនយោបាយរាជរដ្ឋាភិបាលចំពោះជនពិការ
- ផ្តល់ឱកាសការងារ លើកទឹកចិត្តដល់ជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង ចូលបម្រើការងារ
- លើកកម្ពស់សេចក្តីថ្លៃថ្នូរ សុខុមាលភាព និងសិទ្ធិរបស់ជនពិការកម្ពុជាតាមរយៈការទទួលស្គាល់សមត្ថភាពជនពិការ ប្រសើរជាងការមើលឃើញតែពិការភាពរបស់ជនពិការ
- ចូលរួមបំពេញនូវកាតព្វកិច្ចរបស់កម្ពុជាជាហត្ថលេខីនៃអនុសញ្ញា និងគតិកាសញ្ញាដែលទាក់ទងសិទ្ធិមនុស្ស និងសិទ្ធិជនពិការ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានកាតព្វកិច្ចក្នុងការជ្រើសរើសជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ។

**មាត្រា៤.-**

**ការសម្របសម្រួលសមស្របមានបន្ទុកធ្ងន់ធ្ងរហួសហេតុ** សំដៅដល់ការសម្របសម្រួលលើប្រភេទ និងលក្ខខណ្ឌការងារ ការហ្វឹកហ្វឺន ផ្នែកបរិស្ថាន ទីកន្លែងការងារ មធ្យោបាយ សម្ភារបរិក្ខារ ដែលហួសពីលទ្ធភាពរបស់ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល។

## ជំពូកទី២
## ការកំណត់អត្រាជនពិការចូលបម្រើការងារ

**មាត្រា៥.-**

ក្រសួង ស្ថាប័នរដ្ឋ ដែលមានមន្ត្រីរាជការ ចាប់ពី ៥០ (ហាសិប) នាក់ឡើងទៅ ត្រូវតែមានជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារ ដូចកំណត់តាមមាត្រា១១នៃអនុក្រឹត្យនេះ ចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការក្នុងអត្រា២ (ពីរ) ភាគរយ នៃចំនួនមន្ត្រីរាជការសរុប។

ការកំណត់ចំនួនជនពិការឲ្យចូលបម្រើការងារក្នុងកងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៦.-**

នីតិបុគ្គល ដែលមានកម្មករ និយោជិត ចាប់ពី ១០០ (មួយរយ) នាក់ឡើងទៅ ត្រូវមានជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារ ដូចកំណត់តាមមាត្រា១១នៃអនុក្រឹត្យនេះ ក្នុងអត្រា ១ (មួយ) ភាគរយ នៃចំនួនកម្មករ និយោជិតសរុប។

**មាត្រា៧.-**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានមន្ត្រីរាជការ និងកម្មករ និយោជិតតិចជាងចំនួនដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ហើយបានជ្រើសរើសជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ ត្រូវទទួលបានការលើកទឹកចិត្តដូចមានចែងក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

វិធីសាស្ត្រនៃការគណនាជនពិការស្របតាមលក្ខណវិនិច្ឆ័យ ប្រភេទ និងកម្រិតនៃពិការភាពដូចកំណត់ក្នុងមាត្រា២០នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការត្រូវអនុវត្តដូចខាងក្រោម៖

| ប្រភេទការងារ | ប្រភេទពិការភាព | កម្រិតពិការភាព | គណនាចំនួន |
|---|---|---|---|
| មន្ត្រីរាជការ និយោជិត បម្រើការងារពេញម៉ោង | ជនពិការកាយសម្បទា | ធ្ងន់ | ជនពិការ១នាក់ត្រូវគិតជា២នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| | ជនពិការកាយសម្បទា | ស្រាល មធ្យម | ជនពិការ១នាក់ត្រូវគិតជា១នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| និយោជិត បម្រើការងាររយៈពេលខ្លី | ជនពិការកាយសម្បទា | ធ្ងន់ | ជនពិការ១នាក់ត្រូវគិតជា១នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| | ជនពិការកាយសម្បទា | ស្រាល មធ្យម | ជនពិការ១នាក់ត្រូវគិតជាកន្លះនាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |

## ជំពូកទី៣
## បែបបទជ្រើសរើស

**មាត្រា៩.-**

ក្រសួង ស្ថាប័នរដ្ឋ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ នៅក្នុងខែមករា ជារៀងរាល់ឆ្នាំ អំពី ៖

- ចំនួនមន្ត្រីរាជការសរុប លើកលែងកងកម្លាំងប្រដាប់អាវុធ
- ចំនួនជនពិការ ដែលគ្រោងនឹងជ្រើសរើស តាមអត្រាកំណត់
- ចំនួនមន្ត្រីរាជការជាជនពិការកាយសម្បទា កម្រិតស្រាល មធ្យម
- ចំនួនមន្ត្រីរាជការជាជនពិការកាយសម្បទា កម្រិតធ្ងន់
- ចំនួនមន្ត្រីរាជការជាជនពិការសតិបញ្ញា កម្រិតស្រាល មធ្យម
- ចំនួនមន្ត្រីរាជការជាជនពិការសតិបញ្ញា កម្រិតធ្ងន់។

ក្នុងករណី ក្រសួង ស្ថាប័នរដ្ឋ ទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ឲ្យជ្រើសរើសក្របខណ្ឌមន្ត្រីរាជការចូលធ្វើការងារ ត្រូវកសាងផែនការជ្រើសរើសជនពិការតាមអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៥ ខាងលើ ផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាត ។

**មាត្រា១០.-**

នីតិបុគ្គល ដែលមានកម្មករ និយោជិត ចាប់ពី ១០០ (មួយរយ) នាក់ឡើងទៅ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាទៀងទាត់រៀងរាល់ឆ្នាំទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងខែមករា ជារៀងរាល់ឆ្នាំ អំពី ៖

- ចំនួនកម្មករ និយោជិត ធ្វើការពេញម៉ោង សរុប
- ចំនួនកម្មករ និយោជិតជាជនពិការ ដែលគ្រោងជ្រើសរើស តាមអត្រាកំណត់
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតស្រាល មធ្យម ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតធ្ងន់ ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតស្រាល មធ្យម ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតធ្ងន់ ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតស្រាល មធ្យម ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតធ្ងន់ ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតស្រាល មធ្យម ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតធ្ងន់ ធ្វើការរយៈពេលខ្លី ។

ក្នុងករណីដែលនីតិបុគ្គលជ្រើសរើសកម្មករ និយោជិត ជាជនពិការកាយសម្បទា ឬសតិបញ្ញា ចូលធ្វើការមិនទាន់គ្រប់ចំនួនតាមអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវរៀបចំផែនការជ្រើសរើសឡើងវិញ ផ្ញើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមុនដំណាច់ខែធ្នូនៃឆ្នាំ។

**មាត្រា១១.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ប្រភេទការងារ ដែលជនពិការអាចធ្វើបាន ផ្ញើជូនគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលមានកាតព្វកិច្ចជ្រើសរើសជនពិការចូលបម្រើការងារ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ ជាសាធារណៈ។

**មាត្រា១២.-**

កាលបរិច្ឆេទនៃការប្រឡងជ្រើសរើសណាមួយ ដែលអាចមានជនពិការកាយសម្បទា ឬសតិបញ្ញាដែលមានលក្ខណសម្បត្តិ និងសមត្ថភាព ឲ្យចូលក្នុងក្របខណ្ឌមន្ត្រីរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយយ៉ាងតិច ៣ (បី) ខែមុនថ្ងៃបើកឲ្យចូលប្រឡង។ ក្នុងករណីដែលមានការប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ។

ចំពោះការជ្រើសរើសចូលបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថាន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្សព្វផ្សាយយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ។

**មាត្រា១៣.-**

គ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមិនទាន់មានជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាព បំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងតាមអត្រាកំណត់ ដូចមានចែងក្នុង

មាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវកសាងផែនការប្រឡងជ្រើសរើសបំពេញបន្ថែម ឲ្យបានគ្រប់ចំនួនក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ។

ការកសាងផែនការជ្រើសរើសបំពេញបន្ថែម ត្រូវធ្វើជារៀងរាល់ឆ្នាំ។ ក្នុងមួយឆ្នាំៗ ត្រូវជ្រើសរើសឲ្យបានយ៉ាងតិច ៣០ (សាមសិប) ភាគរយ នៃគម្រោងផែនការជ្រើសរើសសរុបរយៈពេល ៣ (បី) ឆ្នាំ។

## ជំពូកទី៤
## ភាតព្វកិច្ច និងការសម្របសម្រួលសមស្រប

**មាត្រា១៤.-**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវមានកាតព្វកិច្ចធ្វើការសម្របសម្រួលសមស្រប សម្រាប់មន្ត្រីរាជការ កម្មករ និយោជិត ឬកូនជាង ឬកម្មសិក្សាការីជាជនពិការ ជាអាទិ៍ ការសម្របសម្រួលលើប្រភេទ និងលក្ខខណ្ឌការងារ ការហ្វឹកហ្វឺន ផ្នែកបរិស្ថាន ទីកន្លែងការងារ មធ្យោបាយ សម្ភារបរិក្ខារ លើកលែងតែ ការសម្របសម្រួលសមស្រប មានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

## ជំពូកទី៥
## ការបង់ភាគទាន ការលើកទឹកចិត្ត និងការពិន័យ

**មាត្រា១៥.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ត្រូវបង់ភាគទានចូលហិបមូលនិធិជនពិការជាប្រាក់ស្មើនឹង៥០ (ហាសិប) ភាគរយ នៃប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការក្នុងមួយខែតាមប្រភេទក្របខណ្ឌ សម្រាប់មន្ត្រីរាជការជាជនពិការ ១ (មួយ) នាក់។

នីតិបុគ្គល ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបង់ភាគទានចូលហិបមូលនិធិជនពិការជាប្រាក់ស្មើនឹង ៤០ (សែសិប) ភាគរយ នៃប្រាក់បៀវត្សអប្បបរមាប្រចាំខែរបស់កម្មករ និយោជិត ក្នុងមួយខែ សម្រាប់កម្មករ និយោជិតជាជនពិការ ១ (មួយ) នាក់។

**មាត្រា១៦.-**

ការបង់ភាគទាន ដូចមានចែងក្នុងមាត្រា១៥ ខាងលើត្រូវអនុវត្តតាមនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ។

**មាត្រា១៧.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលបានបំពេញកាតព្វកិច្ចលើសអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវទទួលបានការលើកសរសើរ និង/ឬការលើកទឹកចិត្តពីរដ្ឋមន្ត្រីក្រសួង

តាមច្បាប់ជាធរមាន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ។

**មាត្រា១៨.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា១៥ នៃ អនុក្រឹត្យនេះ ហើយមិនព្រមបង់ភាគទានចូលហិបមូលនិធិជនពិការ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចមានចែងក្នុងមាត្រា៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

ក្នុងករណីមិនគោរពតាមកថាខណ្ឌខាងលើ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៥៦ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ